អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងផ្គុំពណ៌ជាភ្លើង**

**ចិត្តចលភាព៖** បំណិនចលករតូច៖
ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាចដុំភ្នែក៖
ការរីកចម្រើនរាងកាយនិងចលនា៖
ការរីកចម្រើនកម្លាំងនិងការប្រឈមនិងទប់ទល់ឧបសគ្គពេលធ្វើសកម្មភាពផ្សេងៗ៖

**សិក្សាសង្គម៖** គំនូរនិងសកម្មភាពកសាង៖
ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតជារូបភាព៖

**បុរេគណិត៖** ទំហំនិងពណ៌៖ ចំណាត់ក្រុមនិងលំដាប់លំដោយ៖

**គោលបំណង៖**

**ចិត្តចលភាព៖** **ចរិយាសម្បទា៖** មានអំណត់តស៊ូព្យាយាមនិងសប្បាយរីករាយក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំនិងជោគជ័យ។
**បំណិនសម្បទា៖** អនុវត្តសកម្មភាពមួយដែលមានភាពទន់ភ្លន់ រហ័សរហួន និងរឹងមាំការចាប់ផ្តើមចេញពីចលនាមូលដ្ឋានងាយៗទៅលំបាក ចំនួនពីរឡើងទៅ ក្នុងនោះមានការដើរ រត់ លោត ឬលើសពីនេះ តាមរយៈ ចលនាចរន្ត ហាត់ប្រាណតាមបទចម្រៀង តាមរឿងនិទាន បទភ្លេងនិងល្បែងនានា។

**សិក្សាសង្គម៖** វិជ្ជាសម្បទា៖ បត់ក្រដាសបានជារូបភាពផ្សេងៗ៖ យន្តហោះ ទូក អាវ ភ្នែក…
ចរិយាសម្បទា៖ រហ័សរហួន និងប្រុងប្រយ័ត្នក្នុងការការចាប់កាន់ បត់ សូន គូស ហែក កាត់ និងផាត់ពណ៌។

**បុរេគណិត៖** វិជ្ជាសម្បទា៖ ប្រាប់បានពីការរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំនិងពណ៌
បំណិនសម្បទា៖រៀបរាងធរណីមាត្រឬវត្ថុឱ្យត្រូវតាមចង្វាក់ដដែលៗ ដែលមានរាងឬពណ៌ឬទំហំ។

**កម្រិតសិក្សា** ៖ មធ្យម ខ្ពស់។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ម្សៅពណ៌២ពណ៌ ពណ៌លឿងនិងពណ៌ក្រហម ទុយោរ កែវសម្រាប់ដាក់លាយម្សៅពណ៌ ទឹកសម្រាប់លាយជាមួយម្សៅពណ៌ ក្រដាសរាមស (ក្រដាសរលោងឬក្រាសកាន់តែងាយស្រួលផ្តុំ)។

**ការរៀបចំ**៖ ត្រូវសាកល្បងធ្វើ១ឬ២សម្រាប់បង្ហាញទៅកាន់កុមារមុនពេលចាប់ផ្តើមលេងល្បែងនេះ។

**សេចក្តីណែនាំ** ៖

1. នៅពេលមុនលេងសូមប្រាប់កុមារថាថ្ងៃនេះអ្នកទាំងអស់គ្នានឹងលេងល្បែងមួយដែលមានឈ្មោះថា ល្បែង‹‹**ផ្តុំពណ៌ជាភ្លើង››**
2. តើកូនៗស្គាល់ភ្លើងដែរទេ? តើភ្លើងក្តៅដែរឬទេ? តើកូនៗគួរតែលេងភ្លើងដែរឬទេ?
3. ល្បែងនេះអាចលេងបានសម្រាប់កុមារដែលមានកម្រិតមធ្យមនិងខ្ពស់។
4. បង្ហាញកុមារពីក្រដាសដែលបានធ្វើរួច ដើម្បីឱ្យកុមារបានឃើញនិងមានអារម្មណ៍ចង់លេង
5. ចាក់ទឹកចូលក្នុងកែវសមល្មមនិងបរិមាណនៃម្សៅពណ៌
6. ចាក់ម្សៅពណ៌ចូលក្នុងកែវទឹកកូរឱ្យសព្វ
7. ត្រៀមក្រដាសស
8. យកទុយោរ ២ដាក់លើកែវទឹកពណ៌ទាំង២
9. យកទុយោរជ្រលក់ចូលក្នុងកែវទឹកពណ៌ទី១ ធ្វើយ៉ាងណាឱ្យទឹកពណ៌ជាប់នឹងចុងទុយោរ រួចយកមកបន្តក់នៅលើក្រដាសរួចផ្តុំធ្វើជារូបភ្លើង
10. បន្ទាប់កមយកទុយោរជ្រលក់ចូលកែវទឹកពណ៌ទី ២ យកមកបន្តក់នៅលើក្រដាសរួចផ្តុំឱ្យរត់លើគ្នា ដើម្បីឱ្យក្លាយជាភ្លើងដែលមានពណ៌ទឹកក្រូច។